## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣១រូប និងតាមប្រព័ន្ធអនឡាយចំនួន៣២រូប សរុបចំនួន៦៣រូប។

៤. របៀបវារៈ៖

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- បទបង្ហាញស្តីពីយុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ដោយលោកស្រីវេជ្ជ. ទេព សំណាង អនុប្រធានការិយាល័យបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**៥.១ ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះផ្តោតសំខាន់លើយុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ( Boosted Continuum of Prevention, Care and Treatment for Key Populations, B-CoPCT in Cambodia)។ ប្រធានបទនៃការពិភាក្សានេះ គឺក្នុងគោលបំណងពិនិត្យនូវលទ្ធផលដែលទទួលបានរួមនិងឧបសគ្គនានាដែលអ្នកអនុវត្តផ្ទាល់បានជួបប្រទះ និងដាក់ចេញវិធានការអាទិភាពសម្រាប់ឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាព ឆ្ពោះទៅសម្រេចគោលដៅ។

តាមរយៈនៃការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ខ្ពស់របស់រដ្ឋាភិបាល ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាទទួលបានជោគជ័យក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលអត្រាផ្ទុកមេរោគអេដស៍ បានធ្លាក់ចុះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ តាមការប៉ាន់ប្រមាណអ្នកផ្ទុកមេរោគអេដស៍នៅប្រទេសកម្ពុជាឆ្នាំ២០២១ មានចំនួន ៧៤,០០០នាក់ ដោយមានអត្រាវ៉ាឡង ០,៦% ដោយសម្រេចបាននូវគោលដៅជាតិចំនួន ២ ក្នុងចំណោមគោលដៅចំនួន៣ នៃគោលដៅជាតិ ៩៥.៩៥.៩៥ នាឆ្នាំ២០២៥។ ករណីឆ្លងថ្មីមានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ដោយធ្លាក់ចុះនៅត្រឹមតែ ១,១០០ ក្នុងមួយឆ្នាំ ប៉ុន្តែប្រមាណជា ៧៧% បណ្តាលមកពីក្រុមប្រជាជនគន្លឹះ។

នៅប្រទេសកម្ពុជាមានអត្រាផ្ទុកមេរោគអេដស៍ ៤,៩% ក្នុងចំណោមស្ត្រីបម្រើការនៅសេវាកម្សាន្តសប្បាយ (ឆ្នាំ២០២២) ៤,0% ក្នុងចំណោមក្រុមបុរសរួមភេទនិងបុរស (ឆ្នាំ២០១៩) ៩,៦% ក្នុងចំណោមក្រុមបំប្លែងភេទ និង៥,៧%ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន។ តាមគោលដៅជាតិនឹងបញ្ចុះករណីឆ្លងថ្មី ឱ្យមកនៅត្រឹម ក្រោមមួយនាក់ក្នុងមួយថ្ងៃ និងឆ្លើយតបនឹងការប្រឈមមុខនៃក្រុមប្រជាជនគន្លឹះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដាក់នូវយុទ្ធសាស្ត្រជាតិជាបន្តបន្ទាប់ ជាពិសេសយុទ្ធសាស្ត្រជាតិជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ក៏ដូចជាយុទ្ធសាស្ត្រជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ ។

៥.២ លោកស្រី ឡាញ់ ចរិយា និងលោកស្រីវេជ្ជ. ទេព សំណាង មកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល បានធ្វើបទបង្ហាញពីយុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុម ប្រមឈមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ក្នុងការគ្រប់គ្រងក្រុមប្រជាជនគន្លឹះ។ លោកស្រីទាំងពីរនាក់ ក៏បានបង្ហាញពីបញ្ហាប្រឈមនានា និងដំណោះ

ស្រាយដែលនឹងត្រូវធ្វើចំពោះបញ្ហាទាំងនោះ  សម្រាប់ជូនអង្គប្រជុំពិនិត្យ  ពិភាក្សា  និងសម្រេចកំណត់នូវយុទ្ធវិធី និងសកម្មភាពសម្រាប់ការឆ្លើយតបមាន៖

១.សង្ខេបស្តីពីអេពីដេមីសាស្ត្រជំងឺអេដស៍ក្នុងប្រទេសកម្ពុជា ឆ្នាំ ២០២១

២.HIV Epidemiology – Snapshot and Trends 2021

៣.ទិសដៅឆ្ពោះទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅកម្ពុជា

៤.គោលការណ៍ណែនាំ និយាមបែបបទ និងគោលគំនិត

៥.វិធីសាស្ត្រនៃយុទ្ធវិធីខ្លាំងក្លាសេវាបង្ការ ថែទាំ និងព្យាបាល សម្រាប់ក្រុមប្រឈមមុខខ្ពស់

៧.កញ្ចប់សេវាអប់រំផ្ទាល់ និងអប់រំតាមបែបនិម្មិត(តាមអនឡាយ)

៨.រចនាសម្ព័ន្ធអនុវត្តន៍ និងការគ្រប់គ្រង

៩.រចនាសម្ព័ន្ធអនុវត្តន៍ និងការគ្រប់គ្រងកម្មវិធីអប់រំបង្ការសម្រាប់ក្រុមប្រជាជនប្រឈម
កម្មវិធីអប់រំបង្ការសម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់

១០.ការសហការ ប្រតិបត្តិការ និងការអនុវត្តការប្រាស្រ័យទាក់ទង

១១.HIV Prevention Intervention Coverage by SSI (2021-2023

១២.NCHADS Provide Service

១៣.FEW by EE/Hotspot types coverage

១៤.Positivity Rate by Modalities in (2022)

១៥.HIV Self-Testing (HIVST) Update

១៦.HIV Cascade by Age Group in (2022)

១៨.Trend of PrEP Uptake since start, all site

១៩.បញ្ហា និង ដំណោះស្រាយមាន៖

- ក. ការប្រើឱសថការពារ(ប្រ៊ិព)
- ខ. ការអប់រំផ្ទាល់ និងបែបនិមិត្ត
- គ.ការប្រើស្រោមអនាម័យ និងទឹករំអិល
- ឃ. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់
- ង.ជំងឺកាមរោគ STI
- ច.បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូ PMTCT
- ឆ.ការធ្វើតេស្តរកមេរោគអេដស៍តាមរបៀបផ្សេងៗ
- ជ. បរិយាកាសគាំទ្រ និងការសម្របសម្រួល
- ឈ ចីរន្តរភាពនៃសេវាបង្ការ និងធ្វើតេស្តមេរោគអេដស៍ ដែលដឹកនាំដោយសហគមន៍
- ញ.ប្រព័ន្ធរឹងមាំ និងចីរភាពភាពសម្រាប់សុខភាពRSSH
- ដ.គំនិតច្នៃប្រឌិតនានាសម្រាប់ការបង្ការ

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកនៅសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង និងប្រជុំពិភាក្សាជាមួយក្រុមស្នូលដើម្បីរកដំណោះស្រាយ។ **ឯកឧត្តមបណ្ឌិត** ក៏បានបន្តថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិដែលរួមមាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាពពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមាន ប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជាននាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៕

ថ្ងៃអង្គារ ៩កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ** | អ្នកធ្វើរបាយការណ៍

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

ប្រធានអង្គប្រជុំ

ឈឹម មិនដារ៉ែត

វេជ្ជ. ហួត សេរីវុធ

ស៊ុំ ផល្លា